# ច្បាប់និងគោលនយោបាយពូជដំណាំនៃប្រទេសកម្ពុជា

រៀបចំដោយ: នាយកដ្ឋានដំណាំស្រូវ/អគ្គនាយកដ្ឋានកសិកម្ម

២៩ វិច្ឆិកា ២០១៤

លោក គង់ សំអឿន

# ច្បាប់ស្តីពី

# ការគ្រប់គ្រងពូជដំណាំ
# និង
# សិទ្ធិអ្នកបង្កាត់ពូជដំណាំ

- អនុម័តដោយរដ្ឋសភានៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៨
- អនុម័តដោយព្រឹទ្ធសភា នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ជាស្ថាពរ
- ចុះព្រះហស្តលេខាដោយព្រះនរោត្តម សីហមុនី នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់នេះមាន៩ជំពូក និង៨៤ មាត្រា។

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១**

ច្បាប់នេះមានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឲ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និងការការពារពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**

ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និងការអភិវឌ្ឍន៍ពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

**មាត្រា៣**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ពូជដំណាំ រួមទាំងពូជដំណាំដែលមានស្រាប់ និងពូជថ្មីនៃដំណាំលើកលែងតែការគ្រប់គ្រងដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៤**

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំត្រូវស្ថិតនៅក្រោមដែលសមត្ថកិច្ច នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។